# ព្រះរាជក្រឹត្យ

នស/រកត/០៩២៣/៥១៤១

## ស្ដីពី
## ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ដែលសរសេរជាអក្សរកាត់ថា **គ.ជ.អ.** ជាយន្តការរបស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់គុណភាពអប់រំ តាមរយៈការពង្រឹងគុណភាពសាលារដ្ឋ ចាប់ពីថ្នាក់មត្តេយ្យរហូតដល់មធ្យមសិក្សា ដើម្បីផលិតមូលធនមនុស្សប្រកបដោយចំណេះដឹងនិងជំនាញ សីលធម៌ល្អ ឥរិយាបថល្អ និងសមត្ថភាពប្រកួតប្រជែងខ្ពស់ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែងរបស់សង្គម សេដ្ឋកិច្ច និងទីផ្សារការងារ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ជំពូកទី២
## ភារកិច្ចរបស់ គ.ទ.អ.

**មាត្រា២ .-**

**គ.ទ.អ.** មានភារកិច្ចដូចតទៅ៖

- កំណត់និងដាក់ចេញវិធានការគន្លឹះ ក្នុងការពង្រឹងអភិបាលកិច្ចសាលា ការពង្រឹងចំណេះដឹង វិន័យ សីលធម៌និងឥរិយាបថរបស់សិស្ស ការលើកកម្ពស់សុខភាពរបស់សិស្ស និងការលើកទឹកចិត្តឱ្យមានការចូលរួមរបស់មាតាបិតា អាណាព្យាបាល និងសហគមន៍ក្នុងការអប់រំ ដាក់ចេញវិធានការចាំបាច់ ដើម្បីជំរុញនិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តវិធានការគន្លឹះ
- កំណត់សមិទ្ធកម្មនិងសូចនាករនៃការអនុវត្តវិធានការគន្លឹះ
- ដឹកនាំ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិធានការគន្លឹះ
- តម្រង់ទិសនិងដោះស្រាយបញ្ហាពាក់ព័ន្ធ ដើម្បីធានាស័ក្តិសិទ្ធិភាពនិងប្រសិទ្ធភាពនៃការអនុវត្តវិធានការគន្លឹះ
- សម្របសម្រួលក្នុងកម្រិតគោលនយោបាយនិងយុទ្ធសាស្ត្រលើកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ វិស័យឯកជន និងភាគីពាក់ព័ន្ធ ក្នុងការលើកកម្ពស់វិស័យអប់រំក្នុងការផលិតមូលធនមនុស្ស
- ធានាសង្គតិភាពនៃការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំជាមួយការងារកែទម្រង់ក្នុងវិស័យផ្សេងទៀតរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## សមាសភាពនិងរចនាសម្ព័ន្ធរបស់ គ.ទ.អ.

**មាត្រា៣ .-**

**គ.ទ.អ.** មានសមាសភាពដូចតទៅ៖

| | |
|---|---|
| ១- នាយករដ្ឋមន្ត្រី | ប្រធាន |
| ២- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធានប្រចាំការ |
| ៤- រដ្ឋមន្ត្រីក្រសួងផែនការ | សមាជិក |
| ៥- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៦- រដ្ឋមន្ត្រីក្រសួងព័ត៌មាន | សមាជិក |
| ៧- រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ៨- រដ្ឋមន្ត្រីក្រសួងសុខាភិបាល | សមាជិក |
| ៩- រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ១០- រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា | សមាជិក |
| ១១- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | សមាជិក |
| ១២- រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៣- រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ | សមាជិក |
| ១៤- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១រូប | សមាជិក |
| ១៥- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | សមាជិក។ |

សមាសភាពជាក់ស្តែងនៃ **គ.ទ.អ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**គ.ទ.អ.** អាចមានសមាសភាពបន្ថែមជារដ្ឋមន្ត្រី ប្រធានស្ថាប័ន ឬតំណាងនៃក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតនៃរាជរដ្ឋាភិបាល តាមការចាំបាច់។ សមាសភាពបន្ថែម ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៤ .-**

**គ.ទ.អ.** អាចមានអនុគណៈកម្មាធិការ និង/ឬក្រុមការងារ ដើម្បីបម្រើការងារក្នុងការបំពេញភារកិច្ចដូចមានចែងក្នុងមាត្រា២ តាមការចាំបាច់។ អនុគណៈកម្មាធិការ និង/ឬក្រុមការងាររបស់ **គ.ទ.អ.** ត្រូវបង្កើតឡើងដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៤
## ការប្រព្រឹត្តទៅនៃ គ.ទ.អ.

**មាត្រា៥ .-**

**គ.ទ.អ.** ត្រូវប្រជុំយ៉ាងតិចរៀងរាល់៣(បី)ខែម្ដង តាមការអញ្ជើញរបស់ប្រធាន។

តាមការអញ្ជើញរបស់ប្រធានឬតំណាងដែលទទួលការប្រគល់សិទ្ធិពីប្រធាន អនុប្រធាននិងសមាជិក **គ.ទ.អ.** ត្រូវចូលរួមប្រជុំឬចាត់តាំងតំណាងដែលមានសិទ្ធិសម្រេចឱ្យចូលរួមប្រជុំជំនួស ក្នុងករណីអវត្តមានឬមានធុរៈ។

**គ.ទ.អ.** ប្រើត្រារបស់រាជរដ្ឋាភិបាល សម្រាប់ដំណើរការការងារ។

**មាត្រា៦ .-**

ប្រធាន **គ.ទ.អ.** អញ្ជើញប្រធានស្ថាប័ន ឬតំណាងរបស់ប្រធានស្ថាប័ន ឬអាជ្ញាធរ ព្រមទាំងមន្ត្រីបច្ចេកទេសនៃក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ចូលរួមប្រជុំនិងបំពេញការងារស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

**មាត្រា៧ .-**

**គ.ទ.អ.** និងអនុគណៈកម្មាធិការ ព្រមទាំងក្រុមការងារ អញ្ជើញដៃគូអភិវឌ្ឍ វិស័យឯកជន សង្គមស៊ីវិល ទីប្រឹក្សា ឬអ្នកជំនាញការជាតិ និងអន្តរជាតិ ចូលរួមប្រជុំពិគ្រោះយោបល់ តាមការចាំបាច់។

**មាត្រា៨ .-**

ក្រសួងអប់រំ យុវជន និងកីឡា បំពេញមុខងារជាលេខាធិការដ្ឋានរបស់ **គ.ទ.អ.**។

**មាត្រា៩ .-**

តួនាទីនិងភារកិច្ចរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងក្របខ័ណ្ឌជាលេខាធិការដ្ឋាន **គ.ទ.អ.** ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៥
## ប្រភពធនធានរបស់ គ.ទ.អ.

**មាត្រា១០ .-**

ប្រភពធនធានសម្រាប់ទ្រទ្រង់ **គ.ទ.អ.** មាន ថវិកាជាតិ ថវិកាដៃគូ និងប្រភពស្របច្បាប់ផ្សេងទៀត ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១១ .-**

អាណត្តិរបស់ **គ.ឌ.អ.** នឹងត្រូវបញ្ចប់ដោយស្វ័យប្រវត្តិនៅពេលដែលអាណត្តិរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ត្រូវបានបញ្ចប់។

**មាត្រា១២ .-**

សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ សៅរ៍ ៩រោច ខែ ស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ២០២៣

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ករល.២៣០៩.៤១៥៥

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**